ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ: ៤៥១ ប្រក.កសក

# ប្រកាស

## ស្តីពី

## ការបង្កើតស្ថានីយផ្សព្វផ្សាយ និង ស្តារព្រៃឈើស្ងួតទ្រេត

រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និង ការប្រព្រឹត្តទៅនៃ គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ព្រៃឈើ
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពី ការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញអនុក្រឹត្យលេខ ៦៤ អនក្រ.បក ចុះថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពី ការប្តូរឈ្មោះនាយកដ្ឋានរុក្ខាប្រមាញ់ទៅជារដ្ឋបាលព្រៃឈើ
- បានឃើញប្រកាសលេខ ៥០៩ ប្រក.កសក.បុ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពី ការរៀបចំ និង ការប្រព្រឹត្តទៅរបស់រដ្ឋបាលព្រៃឈើ
- តាមសំណើរបស់ប្រធានរដ្ឋបាលព្រៃឈើ

## សម្រេច

**ប្រការ ១:** បង្កើតស្ថានីយមួយកន្លែងមានឈ្មោះថា **ស្ថានីយផ្សព្វផ្សាយ និង ស្តារព្រៃឈើស្ងួតទ្រេត** ដែលមានទីតាំងនៅលើផ្ទៃដីព្រៃបម្រុងទុកអចិន្ត្រៃយ៍ ស្ថិតនៅឃុំអូរបីជាន់ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ។

**ប្រការ ២:** ការបង្កើតស្ថានីយផ្សព្វផ្សាយ និង ស្តារព្រៃឈើស្ងួតទ្រេតក្នុងគោលបំណង :

- ស្តារព្រៃឈើឡើងវិញ តាមរយៈការដាំឈើសម្រាប់វិស័យសេដ្ឋកិច្ច

អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទលេខ : (០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon Phnom Penh, Cambodia Phone (023) 726 128 / 726 129, Fax (855) 23 - 217 320

- បំផុសការចូលរួមដាំឈើរបស់សហគមន៍មូលដ្ឋាន ដើម្បីបង្កើនជីវភាពរស់នៅរបស់ប្រជាជនក្នុងតំបន់
- អភិវឌ្ឍចំណេះដឹងវិស័យព្រៃឈើដល់សហគមន៍មូលដ្ឋាន
- ទប់ស្កាត់បង្ក្រាប និង លុបបំបាត់ការកាប់រាន ការដុត ការឈូសឆាយ និង ការហ៊ុំព័ទ្ធកាន់កាប់ដីព្រៃឈើដើម្បីជាកម្មសិទ្ធិ
- ទប់ស្កាត់ការហូរច្រោះដីជាតិដី និង កែលំអដីតាមរយៈដំណុះព្រៃ
- កាត់បន្ថយការប្រើប្រាស់ព្រៃឈើធម្មជាតិ ដោយបង្កើនផលិតផលឈើពីព្រៃដាំ
- អភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពនូវសេដ្ឋកិច្ច សង្គម និង បរិស្ថាន ។

**ប្រការ ៣:** ស្ថានីយផ្សព្វផ្សាយ និង ស្តារព្រៃឈើស្ទួលទ្រេតមានផ្ទៃក្រឡាទំហំ ៣.៧៤៤ ហិកតា (បីពាន់ប្រាំពីររយចិតសិបបួនហិកតា) ដូចមានផែនទីមាត្រដ្ឋាន១:៥០.០០០ ភ្ជាប់មកជាឧបសម្ព័ន្ធ និង កំណត់ដោយចំណុចនិយាមការជាប្រព័ន្ធខ្សែព្រំបិទចាប់ពីចំណុច A (261000, 1509000) B (258000, 1512000) C (258000,1519000) D (259000,1519000) ដល់ចំណុច E (265000,1511000 ) ។

**ប្រការ ៤:** ស្ថានីយផ្សព្វផ្សាយ និង ស្តារព្រៃឈើស្ទួលទ្រេត ស្ថិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋបាលព្រៃឈើ និង មានភារកិច្ច ដូចតទៅ :

- ធ្វើការដាំឈើ ថែរក្សាការពារ និង ប្រមូលផលឈើដាំ
- សហការជាមួយដៃគូអភិវឌ្ឍន៍ ដៃគូវិនិយោគក្នុងប្រទេស ឬ ក្រៅប្រទេសក្នុងការដាំដុះ កែច្នៃ និង ធ្វើអាជីវកម្មឈើដាំ
- ជួយបណ្តុះបណ្តាល និង ផ្សព្វផ្សាយបច្ចេកទេសដល់សហគមន៍មូលដ្ឋាន
- ទាក់ទាញគំរោងជំនួយ ពីបណ្តាអង្គការអន្តរជាតិនានា ។

**ប្រការ ៥:** ដំណើរការ និង ការគ្រប់គ្រងស្ថានីយផ្សព្វផ្សាយ និៗ ស្តារព្រៃឈើនេះត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធានរដ្ឋបាលព្រៃឈើ ។

**ប្រការ ៦:** ប្រកាស ឬ សេចក្តីសម្រេចទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៧:** អគ្គនាយកនៃក្រសួង អគ្គាធិការ នាយកខុទ្ទកាល័យ ប្រធានរដ្ឋបាលព្រៃឈើ ប្រធានអង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ដែលពាក់ព័ន្ធត្រូវអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី...១៩...ខែ...ឧសភា...ឆ្នាំ ២០០៧

រដ្ឋមន្ត្រី

ច័ន្ទ សារុន

កន្លែងទទួល :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- សាលាខេត្តបន្ទាយមានជ័យ
- ដូចប្រការ ៧
- ឯកសារ-កាលប្បវត្តិ

# ផែនទី ទីតាំងស្នើសុំបង្កើតស្ថានីយ៍ផ្សព្វផ្សាយ និងស្តារព្រៃឈើ ស្ពួយព្រៃត
# ស្ថិតនៅក្នុងស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ

